# កិច្ចលៀងចេញវស្សា

កិច្ចពិធីពាក់ព័ន្ធជាមួយជំនឿជីវចលនៅតំបន់ប្រាសាទសំបូរព្រៃគុក មានច្រើនបែបច្រើនយ៉ាងណាស់។ រីឯ កិច្ចពិធីធំៗចំនួន៣ដែលគេស្គាល់ គឺ "ឡើងអ្នកតា", "លៀងអារក្ស" និង "ច្រត់ព្រះនង្គ័ល។ ប៉ុន្តែ នៅមានកិច្ចមួយទៀតដែលគេមិនសូវស្គាល់ទូលំទូលាយ ហើយក៏មិនមានប្រារព្ធច្រើនកន្លែងនោះដែរ ពោល គឺ "**កិច្ចលៀងចេញវស្សា**"។ ទោះបីជា "បុណ្យចេញ និងចូលវស្សា" គេស្គាល់ជាទូទៅថា ជាពិធីបុណ្យនៅក្នុងព្រះពុទ្ធសាសនា ដែលមានរយៈពេលចំនួនបីខែក្តី (ចាប់ពីថ្ងៃ១រោច ខែអាសាឍ ដល់ថ្ងៃ១៥កើត ខែអស្សុជ) មនុស្សនៅតំបន់ប្រាសាទសំបូរព្រៃគុកបានភ្ជាប់ពិធីបុណ្យនេះជាមួយជំនឿជីវចល។ តើ "កិច្ចលៀងចេញវស្សា" មានរណ្តាប់ ដំណើរការនៃកិច្ច និងគោលបំណងបែបណាខ្លះ?

កិច្ចនេះ មានប្រារព្ធធ្វើនៅភូមិសំបូរ (ខាងកើតតំបន់ប្រាសាទសំបូរព្រៃគុក) ដែលជាភូមិបុរាណមួយសម្បូណ៌ទៅដោយអ្នកស្នងរូប (គេច្រើនហៅថា "រូប" ឬ "រូបស្នង" ឬ "គ្រូអារក្ស") ពោលយ៉ាងហោចណាស់ក៏បច្ចុប្បន្ននេះមានចំនួន ១៧ នាក់ដែរ។ ប៉ុន្តែ រូបស្នងដែលប្រារព្ធកិច្ចលៀងចេញវស្សានេះ មានតែម្នាក់ប៉ុណ្ណោះ ដែលលោកមានឈ្មោះថា "**លូន**"។ កិច្ចលៀងចេញវស្សា ឬហៅខ្លីថា "លៀង" ច្រើនប្រារព្ធនៅមុន ឬក្រោយចេញវស្សា អាស្រ័យទៅតាមគ្រូអារក្សជាអ្នកកំណត់ តែភាគច្រើនគេរើសយកក្រោយចេញវស្សា។ ពាក្យ "លៀង" ជាពាក្យកម្ចីមកពីភាសាសៀម ដែលប្រែជាខ្មែរថា "ជួបជុំផឹកស៊ី" ឧទាហរណ៍ "ស៊ីលៀង" ឬ "ជប់លៀង" ជាដើម។ ជួនកាលពាក្យនេះ ប្រើក្នុងន័យសំអាត ឬជម្រះមន្ទិល ដែលមានន័យដូចគ្នានឹងពាក្យ "បង្កក់" ដែរ ពោល គឺឱ្យស្អាតរាល់មន្ទិល ឬកង្វល់ផ្សេងៗ។ កិច្ចនេះ ធ្វើឡើងក្នុងគោលបំណងទទួលគ្រូអារក្សបន្ទាប់ពីចាំវស្សាអស់រយៈកាលបីខែ ដើម្បីឱ្យគ្រូអារក្សមកបន្តថែរក្សាសិស្សគណរបស់ខ្លួន។

## គ្រឿងរណ្តាប់

កិច្ចលៀងចេញវស្សា គឺពុំស្មុគស្មាញដូចកិច្ចលៀងអារក្សនោះទេ ពោល គឺបន្ទាប់ពីកំណត់ពេលបានហើយ ចៅមឿងបានជូនដំណឹងដល់សិស្សគណ ស្នំគ្រូអារក្ស និងរូបស្នងដទៃទៀតមកចូលរួម។ លុះដល់ថ្ងៃកំណត់ យើងឃើញស្នំនៃគ្រូអារក្ស និងកូនចៅរូបស្នងបានប្រមូលផ្តុំគ្នារៀបចំ

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

គ្រឿងរណ្តាប់មួយចំនួន ដូចជា អង្ករដ័យ រណ្តាប់សម្រាប់ខ្មោច ជម ស្លាធម៌ និងបាយសីគ្រូ សណ្តោះជាដើម (រូបលេខ១ - ៥)។

## ដំណើរនៃកិច្ចពិធី

ក្រោយពីស្រស់ស្រូបអាហារថ្ងៃត្រង់រួច រូបស្នង ស្នំ និងសិស្សគណបានមកជួបជុំនៅលើផ្ទះប្រារព្ធពិធី។ ប្រសិនបើប្រៀបធៀបនឹងលៀងអារក្សវិញឃើញថា កិច្ចពិធីទាំងអស់ធ្វើនៅក្នុងរោងដាច់ដោយឡែកពីផ្ទះ ហើយធ្វើនៅពេលយប់។ ពិធីនេះ ចាប់ផ្តើមនៅពេលថ្ងៃត្រង់ ដោយរូបស្នងម្ចាស់រោងអង្គុយកាន់តោក ហើយស្មិងស្មាធិ៍មួយសន្ទុះ រួចសង្រ្គប់ទៅលើតោកដែលយើងអាចសន្មតបានថា គ្រូអារក្សបានមកសណ្ឋិតនៅក្នុងខ្លួនរូបស្នងហើយ។ តោក ជារណ្តាប់មួយដ៏សំខាន់ដែលរូបស្នងពុំអាចខ្វះបានក្នុងការផ្ទេររូបគ្រូអារក្សមកសណ្ឋិតក្នុងខ្លួនរូបស្នង។ ក្នុងករណីដែលពុំមានតោក អ្នកស្រុកប្រើផ្តិលជំនួសវិញ តែគេនៅតែហៅថា "តោក" ដដែល។ នៅក្នុងតោកនោះមានធូប ទៀន អំបោះ ពែងតូច ជន្ទាប់ ក្រមួន កូនសៀងដាក់អង្ករ និងលុយ។ បន្ទាប់ពីគ្រូអារក្សសណ្ឋិតក្នុងខ្លួនរូបស្នងហើយ រូបឡើងរាំកម្សាន្ត និងស្តោះផ្លុំជូនដល់សិស្សគណរបស់ខ្លួនដូចពិធីលៀងអារក្សដែរ តែពុំយូរដូចពិធីលៀងអារក្សនោះឡើយ ពោល គឺធ្វើតែមួយល្ងាចប៉ុណ្ណោះ ហើយកិច្ចនេះក៏បញ្ចប់ត្រឹមប៉ុណ្ណឹងដែរ (រូបលេខ៦-៧)។ នៅថ្ងៃបន្ទាប់ពីកិច្ចលៀងចេញវស្សា ម្ចាស់ផ្ទះបានរៀបចំកិច្ចមួយទៀតហៅថា "**ត្រាស់គ្រូ**" ហើយសិស្សគណដែលនៅក្បែរនោះ នាំគ្នាទៅផ្ទះគ្រូរបស់ខ្លួនដើម្បីធ្វើកិច្ចនេះ។ នៅក្នុងកិច្ចត្រាស់គ្រូ មានការបញ្ឆាន់រូបដូចគ្នា ដើម្បីរៀបរាប់ដំណើរនៃកិច្ចពិធីប្រាប់គ្រូ និងសុំគ្រូអនុគ្រោះរាល់កំហុសឆ្គងទាំងឡាយដែលមាន។

ជារួមមក ពិធីនេះមានលក្ខណៈពិសេសដាច់ដោយឡែកពីកិច្ចជំនឿជីវចលផ្សេងៗទៀត ពោល គឺប្រារព្ធបន្ទាប់ចេញវស្សា ដែលសបញ្ជាក់ឱ្យឃើញអំពីទំនាក់ទំនងរវាងជំនឿជីវចលជាមួយជំនឿព្រះពុទ្ធសាសនា ដូចដែលគេឃើញមានជាច្រើនរូបភាពនៅក្នុងពិធីបែបជីវចលជាច្រើនកន្លែង។ រីឯរណ្តាប់និងដំណើរការនៃកិច្ចមិនសូវខុសគ្នាពីកិច្ចលៀងអារក្សប៉ុន្មានឡើយ គ្រាន់តែខុសត្រង់ថាគេប្រារព្ធឡើងដើម្បីទទួលគ្រូអារក្សបន្ទាប់ពីចាំវស្សាអស់រយៈកាលបីខែ និងសុំឱ្យគ្រូអារក្សមកបន្តថែរក្សាសិស្សគណរបស់ខ្លួន។

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

## បញ្ជីឯកសារពិគ្រោះ

**ម៉ង់ វ៉ាលី, អាន រស្មី, ស្រី សមប៊ុនណារ៉ុង**

២០២៥, *មត៌កអរូបីជុំវិញតំបន់សំបូរព្រៃគុក (ការសិក្សាស្រាវជ្រាវ និងចុះបញ្ជីកិច្ចពិធីបែបជីវចល)*, ភ្នំពេញ។

**ម៉ង់ វាលី**

"លៀងអារក្សនៅភូមិសំបូរ", អត្ថបទផ្សាយអនឡាញនៅក្នុង *AMS Khmer civilization*, https://khmercivilization.ams.com.kh/detail/29792។

**ស្រេង ជីវ័ន្ត**

២០២៥, *សញ្ញាណ "ស្នង" ក្នុងកិច្ចពិធី*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា, ជំនាន់ទី៣៣, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

**អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា និងស៊ុន ចាន់ដឹប**

២០១៤, *ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ*, យសោធរ, ភ្នំពេញ។

**ANG Chouléan**

1986, *Les êtres surnaturels dans la religion*, Cedoreck, Paris.



រូបលេខ២១៖ អង្ករជ័យ



រូបលេខ២២៖ រណ្ដាប់សម្រាប់ខ្មោច



រូបលេខ២៣៖ ជម៨ ស្លាធម៌ធំ២ ស្លាធម៌តូច៤



រូបលេខ២៤៖ បាយសីគ្រួសណ្ដោះ



រូបលេខ២៥៖ ជមក្អេង

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ២៦៖ គ្រូអារក្សឡើងរាំកម្សាន្ត



រូបលេខ២៧៖ គ្រូអារក្សស្តោះផ្លុំឱ្យសិស្សគណ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង